01220676

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**D284/1/4**

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៥)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ជាប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន័យ ធុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ៣១ ខែ កុម្ភៈ ឆ្នាំ ២០១៦**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 03 / 2016
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ (សំណៅកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ**
**D193/47, D193/49, D193/51, D193/53, D193/56 និង D193/60**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍**
មុំ លុជ្ឈ
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01220677



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានចេញកាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ពាក់ព័ន្ធចម្លើយរបស់ [redacted] តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ("ដីកាសម្រេចដែលរងការជំទាស់")[2]។

### ក. សាវតារ

2. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់ [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") នៅក្នុងអំពើឧក្រិដ្ឋកម្ម និងបានស្នើសុំឱ្យចោទប្រកាន់ប្រឆាំងនឹងរូបគាត់[3]។

3. នៅចន្លោះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ និងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើចំនួន ២៦ សុំដាក់បង្ហាញសម្ភារៈពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេច ឬដីកាសម្រេចពាក់ព័ន្ធចំនួន ២៥[5]។

---

[1] ឯកសារ D284/1/2 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសម្រេចលើចម្លើយតបរបស់ [redacted] ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D284 ("ដីកាសម្រេចដែលរងការជំទាស់")។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារ D1។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៩, ឯកសារ D1/1។

[4] *សូមមើល* D167, D167/2, D193, D193/2, D193/3, D193/5, D193/7, D193/9, D193/12, D193/14, D193/17, D193/20, D193/23, D193/25, D193/26, D193/27, D193/29, D193/31, D193/32, D193/35, D193/36, D193/38, D193/39, D193/40, D193/42, និង D200។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE C.C.C. C.E.T.C.

4. នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ អង្គបុរេជំនុំជម្រះបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់សហមេធាវី [redacted] ប្រឆាំងការបដិសេធតាមការសន្មតចំពោះសំណើសុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយរបស់សាក្សីក្នុងសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២/០២ ដោយសារតែម្ចាស់បណ្តឹងឧទ្ធរណ៍មិនមានសិទ្ធិប្តឹងទេ[6]។

5. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍បានចូលរួមក្នុងការបង្ហាញខ្លួនជាលើកដំបូង ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់គាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បន្ថែមពីលើបទចោទដទៃទៀត ដែលស្ថិតក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ[7]។

6. នៅចន្លោះពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥ និងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើបន្ថែមចំនួនប្រាំមួយ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ (ជារួមហៅថា "សំណើសុំដាក់បង្ហាញឯកសារ") ដែលសំណើទាំងអស់ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយ ឬកំណត់ហេតុកិច្ចស៊ើបអង្កេត ពាក់ព័ន្ធការជំនុំជម្រះដែលកំពុងអនុវត្ត និងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២[8]។

---

[5] *សូមមើល* D167/1, D167/3, D193/1, D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15, D193/16, D193/19, D193/21, D193/24, D193/28, D193/30, D193/33, D193/34, D193/37, D193/41, D193/43, D193/44, D193/49, D200/1, D200/2, និង D200/4។

[6] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការពិចារណាឡើងវិញ លើការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ D229/1/2។

[7] កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូង, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥, ឯកសារ D242។

[8] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥, [redacted] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ [redacted]

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51 D193/53, D193/56 និង D193/60*

7. នៅចន្លោះពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ សហមេធាវីម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់ចម្លើយចំនួនប្រាំតបទៅទៅនឹង សំណើសុំដាក់បង្ហាញឯកសារ (ជារួមហៅថា "ចម្លើយតប")[9]។

---

[redacted] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥, ឯកសារ D193/48 [redacted] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥, ឯកសារ D193/50 [redacted] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥, ឯកសារ D193/52 [redacted] សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D193/58 [redacted]

[9] ចម្លើយតបរបស់ [redacted] ចំពោះសំណើជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥, ឯកសារ D193/47។ ចម្លើយតបរបស់ [redacted] ចំពោះសំណើ D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥, ឯកសារ D193/49។ ចម្លើយតបរបស់ អោ អាន ចំពោះសំណើជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/50 សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D193/51។ ចម្លើយតបរបស់ [redacted] ចំពោះសំណើជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/52 សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥, ឯកសារ D193/53។ ចម្លើយតបរបស់ [redacted] ចំពោះសំណើជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/58 សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D193/60។

8. នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបរួមចំពោះចម្លើយតបបួន[10]។

9. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥, និងថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេចចំនួនប្រាំ លើសំណើសុំដាក់បង្ហាញឯកសារ[11]។

10. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ សហមេធាវីម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធសេចក្តីសម្រេចថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[12]។

11. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដែលរងការជំទាស់ ដោយបដិសេធសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំឱ្យបញ្ឈប់ការដាក់បង្ហាញឯកសារ និងផ្លាស់ប្តូរលក្ខខណ្ឌសម្រាប់ការដាក់បង្ហាញ ដែលបានធ្វើឡើងក្នុងចម្លើយតប។

---

[10] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ [redacted] (D193/47, D193/49, D193/51 & D193/53) ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥, ឯកសារ D193/54។

[11] ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលក្នុងសំណុំរឿង ០០២/០១,ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥, ឯកសារ D193/55។ ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/52 សុំដាក់បង្ហាញឯកសារ,ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥, ឯកសារ D193/57។ ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/58 សុំដាក់បង្ហាញឯកសារ,ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D193/59។ ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 សុំដាក់បង្ហាញឯកសារ,ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D193/61។ សេចក្តីសម្រេចផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង នូវឯកសារដែលដាក់បង្ហាញពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ជូនទៅអង្គជំនុំជម្រះតុលាការកំពូល ក្នុងឯកសារ D193/55 និង D193/57, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦, ឯកសារ D193/62។

[12] សំណើសុំការបញ្ជាក់ចំពោះសេចក្តីសម្រេច លើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥, ឯកសារ D193/56។

## ខ. បណ្តឹងឧទ្ធរណ៍

12. នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ សហមេធាវីបានដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចដែលរងការជំទាស់[13]។

13. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ សហមេធាវីបានដាក់សំណើសុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសសិន ហើយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[14]។

14. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ ជាភាសាអង់គ្លេស។ បណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងដល់ភាគីនានាជាភាសាអង់គ្លេស នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ និងជាភាសាខ្មែរនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង និង/ឬតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[15] ហើយបានលើកនូវមូលដ្ឋានចំនួនបីនៃបណ្តឹងឧទ្ធរណ៍ ផ្អែកលើការចោទប្រកាន់ពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ[16]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើដល់អង្គបុរេជំនុំជម្រះសុំឱ្យប្រាទចោទដីកាសម្រេចដែលរងការជំទាស់ ហើយបង្គាប់ដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឱ្យ “លុបចោលនូវដីកាសម្រេច និងសេចក្តីសម្រេចទាំងអស់ពីមុនៗ ស្តីពីការដាក់បង្ហាញសម្ភារៈពីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ដែលផ្អែកលើកំហុសនានា ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ”[17]។

[13] ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ប្រឆាងដីកាសម្រេចលើចម្លើយតបរបស់ [redacted] ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥, ឯកសារ D284/1។

[14] សំណើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេសមុននូវ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើការឆ្លើយតបរបស់ [redacted] ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦, ឯកសារ D284/1/1។

[15] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ២៩។

[16] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤, ៤៨ ដល់៧៦។

[17] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៥, ៧៨។

01220682



15. សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតប នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលត្រូវបានជូនដំណឹងទៅភាគីនានា នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦[18]។

## II. ភាពអាចទទួលយកបាន

16. ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន តាមការបកស្រាយក្នុងន័យទូលាយទៅលើវិធាន ៧៤(៣)(ខ) និង/ឬ វិធាន ២១ នៃវិធានផ្ទៃក្នុង[19] ដោយសារតែសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើសុំដាក់បង្ហាញឯកសារ ប៉ះពាល់ដល់សិទ្ធិជាសារវ័ន្តរបស់គាត់ ដែលជាចំណុចសំខាន់នៃភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដែលរួមទាំងសមភាពនៃមធ្យោបាយតទល់រឿងក្ដី សុចរិតភាពនៃកិច្ចស៊ើបអង្កេត និងសច្ចធារណ៍នៃនិរទោស[20]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានបញ្ជាក់ថា ដោយសារតែឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៤ ត្រូវបានប្រើប្រាស់ក្នុងសវនាការសាធារណៈ ក្នុងសំណុំរឿង ០០២ ដើម្បីសួរសាក្សីអំពីមុខងាររបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងតួនាទីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ "ការសន្មតជាមុនថាគាត់គ្មានទោស និងកេរ្តិ៍ឈ្មោះរបស់គាត់ ត្រូវបានរំលោភយ៉ាងច្បាស់ក្រឡែតរួចទៅហើយ"[21] ហើយ "អានុភាពត្រួតនៃការរំលោភភាពសម្ងាត់ដែលកំពុងមាន និងដែលអាចមាន និងការប៉ះពាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ [redacted] និងកេរ្តិ៍ឈ្មោះរបស់គាត់ បានកំពុងបណ្ដាលឱ្យសុចរិតភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ រងការប៉ះទង្គិចដែលមិនអាចជួសជុលបាន"[22]។

17. សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបានឡើយ ផ្អែកតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ មិនមែនពាក់ព័ន្ធនឹង

---

[18] ចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចលើចម្លើយតបរបស់ [redacted] ឯកសារ D193/47, D193/49, D193/51, D193/53 & D193/60, ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦, ឯកសារ D284/1/3 ("ចម្លើយតប")។

[19] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ២៦ ដល់៣០។

[20] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ២៩។

[21] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ៧៣ ដល់៧៥។

[22] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ៧៦។

សេចក្តីសម្រេចលើការដាក់បង្ហាញហើយ[23]។ យោងតាមសារណារបស់គាត់ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា ការអន្តរាគមន៍របស់អង្គជំនុំជម្រះជាការចាំបាច់ ផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីរាំងព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ឡើយ[24]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងបន្ថែមថា មិនមានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ណាដែលអាចការពារសុចរិតភាពនៃកិត្តិយសរបស់ជនត្រូវចោទ[25] ឬសិទ្ធិទទួលបានការស៊ើបអង្កេតដោយសម្ងាត់ឡើយ[26]។

18. ជាដំបូង អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ផ្នែកទីពីរនៃបណ្តឹងឧទ្ធរណ៍ស្នើសុំលុបចោល "ដីកាសម្រេច និងសេចក្តីសម្រេចទាំងអស់ពីមុនៗ ស្តីពីការដាក់បង្ហាញសម្ភារៈពីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ដែលផ្អែកលើកំហុសនានាដែលបានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ"[27] មានភាពមិនច្បាស់លាស់ដែលមិនអាចអនុញ្ញាតបានឡើយ។ អង្គបុរេជំនុំជម្រះសូមរំឮកពីប្រវត្តិដ៏វែងឆ្ងាយនៃសំណើសុំដាក់បង្ហាញឯកសារទៅក្នុងសំណុំរឿង ០០៤ ហើយសម្រេចថាមិនអាចរំពឹងទុកថាខ្លួនត្រូវធ្វើការពិចារណាទៅលើការជំទាស់របស់ភាគីឡើយ ប្រសិនបើភាគីមិនផ្តល់ការយោងច្បាស់លាស់ទៅការសម្រេចដែលខ្លួនជំទាស់ និងទឡ្ហីករណ៍គាំទ្រទេនោះ។ ហេតុដូច្នេះផ្នែកនៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានច្រានចោលភ្លាមៗ។

19. ឥឡូវនេះ អង្គបុរេជំនុំជម្រះងាកទៅពិនិត្យលើភាពអាចទទួលយកបាននៃផ្នែកទីមួយរបស់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់ ដែលច្រានចោលសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ សុំឱ្យបញ្ឈប់ការដាក់បង្ហាញទៅក្នុងសំណុំរឿង ០០២ ឬក៏ផ្លាស់ប្តូរលក្ខខណ្ឌនៃការដាក់បង្ហាញ។

20. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖

---

[23] ចម្លើយតប, កថាខណ្ឌ ៦។

[24] ចម្លើយតប, កថាខណ្ឌ ៧ ដល់១៨។

[25] ចម្លើយតប, កថាខណ្ឌ ១១។

[26] ចម្លើយតប, កថាខណ្ឌ ១៤។

[27] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៥, ៧៨។

**វិធាន ២១: គោលការណ៍ជាសារវ័ន្ត**

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និងជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាព រវាងសិទ្ធិរបស់ភាគីទាំងឡាយ។

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។

21. អង្គបុរេជំនុំជម្រះបានសម្រេចក្នុងពេលកន្លងមកថា គោលការណ៍ជាសារវន្តដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលបានឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត ដោយអនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក")[28] មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[29] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[30] អាចតម្រូវឱ្យ អ.វ.ត.ក អនុម័តយកការបក

---

[28] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹង ការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុង រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។

[29] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[30] សូមមើល, ជាឧទាហរណ៍, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ ៦៤), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០, ឯកសារ A371/2/12, កថាខណ្ឌ ១៣ ដល់១៨, ២៧។

ស្រាយបែបទូលាយអំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងចំពោះមុខ ហើយរក្សាបាននូវតុល្យភាពរបស់សិទ្ធិភាគី[31]។ ក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈជាក់ស្តែងនៃរឿងក្តីតម្រូវនោះ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហានៃសិទ្ធិជាសារវន្ត ឬ "បញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌" អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[32]។ ប៉ុន្តែ វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់នូវមធ្យោបាយស្វ័យប្រវត្តិ

---

[31] សូមមើល, ជាឧទាហរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នា របស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥, ឯកសារ D208/1/1/2, *កថាខណ្ឌ ៨*។ សំណុំរឿង០០៣/*០៧-០៩-២០០៩-អវតក/កសចស* ("សំណុំរឿង ០០៣") (អបជ ១៣), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យពាក់ព័ន្ធដីកាកោះហៅ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែមួយរូប, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤, ឯកសារ D117/1/1/2 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ពាក់ព័ន្ធដីកាកោះហៅ"), *កថាខណ្ឌ ១៥*។ សូមមើលផងដែរ សំណុំរឿង ០០២ (អបជ ១១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងដីកាសម្រេចលើសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែរបស់ភាគី, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារ A190/I/20, កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ ៧១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D390/1/2/4 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងការដាក់ចម្លើយតប"), កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ ១៤), សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តី ស្តីពីកំហុសឆ្គងក្នុងការបកប្រែ, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ("សេចក្តីសម្រេចលើកំហុសឆ្គងក្នុងការបកប្រែ"), កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ ៧៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១,ឯកសារ D427/1/30, កថាខណ្ឌ ៤៩។

[32] ជាឧទាហរណ៍ នៅពេលដែល "ភាពធ្ងន់ធ្ងរ និងភាពមិនប្រក្រតីនៃបញ្ហាយុត្តិធម៌ ដែលកើតឡើងដោយសារការបំពានបំពានទៅលើសិទ្ធិដំណើរការ និងផលប៉ះពាល់របស់វា ចំពោះកិច្ចដំណើរការនីតិវិធី តម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍" ឬ ក្នុងករណីមានការថ្លឹងថ្លែងដែលផលប្រយោជន៍យុត្តិធម៌ ធ្ងន់ជាង "ផលប្រយោជន៍ក្នុងការរក្សាធនធានតុលាការ និងជម្រុញដំណើរការគតិយុត្តិ និងនីតិវិធី"។ *សូមមើល* សំណុំរឿង ០០២ (អបជ ១៤៥ និង១៤៦) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងដីកាដំណោះ ស្រាយ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ D427/2/15 ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងដីកាដំណោះ ស្រាយ"), កថាខណ្ឌ ៧៣ ដកស្រង់ សំណុំរឿង ០០២ (អបជ ៤២),សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធិ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី ដោយផ្អែកលើមូលដ្ឋាននៃការបំពានបំពានដំណើរការ (D264/1), ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០, ឯកសារ D264/2/6, កថាខណ្ឌ ១៤។ សំណុំរឿង ០០២ (អបជ ៣៨), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60*

សម្រាប់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីទឡ្ហីករណ៍ផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ឡើយ[33]។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធានដែលបានលើកឡើងខាងលើ ម្ចាស់បណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីដែលកំពុងពិនិត្យនេះ ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះគឺជាការចាំបាច់ដើម្បីរារាំងព្យសនកម្មដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍។

22. អង្គបុរេជំនុំជម្រះសូមរំឭកថា អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលគួរត្រូវបានបកស្រាយថាជា "សំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេត ឬក៏មន្ត្រីនគរបាលយុត្តិធម៌របស់ អ.វ.ត.ក តាមរយៈដីកាចាត់ឱ្យសួរជំនួស បំពេញកិច្ចណាមួយ ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត"[34]។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ដីកាសម្រេចដែលរងការជំទាស់ ទាក់ទងនឹងសំណើដាក់បង្ហាញឯកសារ ដែលជាសំខាន់ មិនមានគោលដៅប្រមូល ភស្តុតាងនៅក្នុងសំណុំរឿងបច្ចុប្បន្នឡើយ ប៉ុន្តែដើម្បីដាក់បង្ហាញសម្ភារៈភស្តុតាងទៅស្ថាប័នតុលាការដទៃទៀតរបស់ អ.វ.ត.ក និងភាគីនានាដែលបង្ហាញខ្លួននៅចំពោះស្ថាប័នទាំងនោះប៉ុណ្ណោះ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍មិនស្ថិតក្នុងយុត្តាធិការលើរឿងក្តីរបស់អង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ។

23. អង្គបុរេជំនុំជម្រះបានពិចារណាបន្ថែមទៀតថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា សិទ្ធិដែលគាត់បានអះអាង អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង នឹងមានហានិភ័យដែលអាចទទួលការ

---

សហចៅក្រមស៊ើបអង្កេត ស្តីពីសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, ឯកសារ D97/15/9, កថាខណ្ឌ ៣៤, ៣៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ពាក់ព័ន្ធការដាក់ចម្លើយតប, កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើកំហុសឆ្គង ក្នុងការបកប្រែ, កថាខណ្ឌ ២ ដល់៦។

[33] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងដីកាដំណោះស្រាយ, កថាខណ្ឌ ៧២, ៧៣។

[34] សំណុំរឿង ០០២ (អបជ ២៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារD164/3/6, កថាខណ្ឌ ១៨ ដកស្រង់ សំណុំរឿង ០០២ (អបជ ១១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងដីកាសម្រេចលើសិទ្ធិ និងកាតព្វកិច្ចក្នុង[illegible]របស់ភាគី, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារ A190/I/20, កថាខណ្ឌ ២៨។

ប៉ះពាល់ដែលមិនអាចជួសជុលបាន ប្រសិនបើមិនកែប្រែដីកាសម្រេចដែលរងការជំទាស់នោះទេ។ ជាពិសេស អង្គបុរេជំនុំជម្រះមិនមើលឃើញពីមូលដ្ឋានក្នុងការបកស្រាយរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ចំពោះមាត្រា ៨៣ និង ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ២១ និង ៥៦(១) នៃវិធានផ្ទៃក្នុង ដែលថាបានផ្តល់ឱ្យគាត់នូវ "សិទ្ធិដែលមានជាប់មកជាមួយ" ក្នុងការទទួលបានសុចរិតភាព នៃការអនុវត្តកិច្ចស៊ើបអង្កេត កិច្ចស៊ើបអង្កេតដោយសម្ងាត់ ឬការការពារកិត្តិយសរបស់គាត់[35]។ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា ក្របខណ្ឌច្បាប់ អ.វ.ត.ក ជាពិសេសនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង បានផ្តល់ឆន្ទានុសិទ្ធិទូលាយដល់សហចៅក្រមស៊ើបអង្កេតក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ និងផ្តល់សិទ្ធិតិចតួចក្នុងការចូលរួមក្នុងការស៊ើបអង្កេតរបស់តុលាការ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញពីកាលៈទេសៈចាំបាច់ផ្សេងៗដែលតម្រូវឱ្យមានការអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះចំពោះបញ្ហាទាំងនេះឡើយ។

24. អង្គបុរេជំនុំជម្រះក៏ជឿថា សិទ្ធិដែលបានកំណត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ការទទួលបានសមភាពនៃគូភាគី និងសច្ចធារណ៍នៃនិរទោស មិនស្ថិតក្នុងហានិភ័យក្នុងការទទួលរងការប៉ះពាល់ដែលមិនអាចជួសជុលបាន ដោយសារដីកាសម្រេចដែលរងការជំទាស់នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ឡើយ។ អង្គជំនុំជម្រះយល់ថា ការដែលគ្រាន់តែបង្ហាញឈ្មោះម្ចាស់បណ្តឹងឧទ្ធរណ៍ មុខងារ ឬតួនាទីនៅក្នុងសំណុំរឿង ០០២[36] គឺជារឿងមិនអាចជៀសបានឡើយ ដោយសារតែអង្គហេតុ និងភស្តុតាងជាន់គ្នា ហើយការបង្ហាញព័ត៌មានទាំងនេះក៏មិនមែនជាការរំលោភបំពានទៅលើភាពយុត្តិធម៌ ឬការកែប្រែបន្ទុកក្នុងការបង្ហាញភស្តុតាងនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះឡើយ។ ជាចុងក្រោយ អង្គបុរេជំនុំជម្រះរំឭកថា អង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការដោះស្រាយបញ្ហាបែបសម្បត្តិកម្មឡើយ[37] ហើយកត់សម្គាល់ថា ឥទ្ធិពលចំពោះសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុង

[35] សូមមើល, ជាឧទាហរណ៍, បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ២៩, ៤៤, ៧៣។

[36] សូមមើល, ជាឧទាហរណ៍, បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៧៤។

[37] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ពាក់ព័ន្ធដីកាកោះ, *កថាខណ្ឌ* ១៥ ដកស្រង់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ សុំការបញ្ជាក់បំភ្លឺ, ថ្ងៃទី១៣ ខែ[illegible] ឆ្នាំ២០១៤, ឯកសារ D205/1/1/2។

ដោយសារតែការដាក់បង្ហាញសម្ភារឯកសារដែលអាចមាននាពេលអនាគត ទៅក្នុងសំណុំរឿង ០០២ នៅតែជាការស្មានប៉ុណ្ណោះ នៅក្នុងដំណាក់កាលនេះ។

25. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន។

## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ច្រានចោល**បណ្តឹងឧទ្ធរណ៍ ដោយកំណត់ថា មិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**